**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៤៧...សសរ...

**សេចក្តីសំរេច**

**ស្តីពី**

**ការបង្កើតគណៈកម្មការសម្របសម្រួលគំរោងជំនួយផ្នែកព្រហ្មទណ្ឌ**

**និងយុត្តិធម៌របស់ប្រទេសអូស្ត្រាលីសំរាប់ព្រះរាជាណាចក្រកម្ពុជា**

៛

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- យោងអនុស្សរណៈយោគយល់រវាងរាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលអូស្ត្រាលីចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ១៩៩៤
- យោងតាមការចាំបាច់

# សំរេច

**ប្រការ១ :** បង្កើតគណៈកម្មការសំរបសំរួលគំរោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌របស់ប្រទេសអូស្ត្រាលីសំរាប់ព្រះរាជាណាចក្រកម្ពុជាដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **ញឹក សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២- ឯកឧត្តម **ស៊ុយ នូ** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣- ឯកឧត្តម **អ៊ី ជន** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៤- ឯកឧត្តម **សត់ សេដ្ឋា** | អគ្គនាយករដ្ឋបាលក្រសួងមហាផ្ទៃ | សមាជិក |
| ៥- ឯកឧត្តម **ឃីម បូរ** | អភិបាលរងទី១ ខេត្តកណ្តាល | សមាជិក |
| ៦- ឯកឧត្តមឧត្តមសេនីយ៍ឯក **តេង សាវង្ស** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៧- លោកឧត្តមសេនីយ៍ទោ **នេត សាវឿន** | ប្រធាននាយកដ្ឋានកណ្តាលយុត្តិធម៌ ក្រសួងមហាផ្ទៃ | សមាជិក |
| ៨- តំណាងមកពីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ (AusAID) | | សមាជិក |

គណៈកម្មការសំរបសំរួលគំរោងអាចនឹងស្នើឱ្យមានសមាជិកប្រឹក្សាដែលមានចែងក្នុងប្រការ៥ និងសមភាគីគំរោងដែលមានចែងក្នុងប្រការ៦ ដើម្បីឱ្យជួយគាំទ្រដល់គណៈកម្មការនេះ រួមបញ្ចូលទាំងការចូលរួមក្នុងអង្គប្រជុំតាមតម្រូវការចាំបាច់ ។

គណៈកម្មការសំរបសំរួលគំរោងអាចនឹងអញ្ជើញអ្នកចូលរួមចំណែកដទៃទៀត ដើម្បីចូលរួមក្នុងអង្គប្រជុំរបស់គណៈកម្មការសំរបសំរួលគំរោងដើម្បីធ្វើឱ្យប្រសើរឡើងនូវការសំរបសំរួលរវាងផ្នែកសំខាន់ៗនៃប្រព័ន្ធយុត្តិធម៌ ។ អ្នកចូលរួមចំណែកទាំងនោះរាប់បញ្ចូលទាំងតំណាងមកពីស្ថាប័នដទៃរបស់រាជរដ្ឋាភិបាលកម្ពុជារួមមាន ក្រសួងសុខាភិបាល ក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ម្ចាស់ផ្តល់ជំនួយ និង ទីភ្នាក់ងារអង្គការសហប្រជាជាតិ សង្គមស៊ីវិល ព្រមទាំងអង្គការផ្សេងៗទៀតដែលធ្វើការក្នុងផ្នែកយុត្តិធម៌នេះ ។

**ប្រការ២:** គណៈកម្មការសំរបសំរួលគំរោងត្រូវជួបប្រជុំគ្នាយ៉ាងតិច ២ដងក្នុងមួយឆ្នាំ ហើយទទួលខុសត្រូវរាល់ការអភិវឌ្ឍន៍គោលនយោបាយ ការធ្វើផែនការ ការសំរបសំរួល ការត្រួតពិនិត្យ និងការដឹកនាំជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជា ព្រមទាំងអនុវត្តមុខនាទីដូចតទៅនេះ ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការរបស់គំរោង :

- ទទួលខុសត្រូវក្នុងការសំរបសំរួល ការអនុវត្តនីគំរោងជំនួយផ្នែកព្រហ្មទ័ណ្ឌនិងយុត្តិធម៌នៅកម្ពុជាដើម្បីធានាឱ្យរាល់សកម្មភាពទាំងឡាយរបស់គំរោងនេះបានដំណើរការស្របតាមកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលអូស្ត្រាលី ជាមួយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- ពិនិត្យឡើងវិញនូវផែនការប្រចាំឆ្នាំ រាប់បញ្ចូលទាំងសកម្មភាពដែលត្រូវបានអនុវត្ត ថវិកា ទិញគ្រឿងបរិក្ខារ និងឧបករណ៍សំភារៈ ព្រមទាំងការរៀបចំចាត់ចែងមន្ត្រីបុគ្គលិក ។
- ពិនិត្យឡើងវិញនិងរាយការណ៍តាមកាលកំណត់ជាទៀងទាត់ជូនដល់រដ្ឋាភិបាលទាំងពីរ លើការរីកចំរើនផែនការការងារ និងថវិកា ។
- ផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលទាំងពីរ នូវការផ្លាស់ប្តូរដ៏សមស្របណាមួយក្នុងគំរោងរាប់បញ្ចូលទាំងថវិកា និងការរីកចំរើននាពេលអនាគត ស្របទៅតាមផែនការការងារប្រចាំឆ្នាំនិងថវិកាដែលសំរេចដោយរដ្ឋាភិបាលទាំងពីរ ។
- រៀបចំរបាយការណ៍សង្ខេបដោយគូសបញ្ជាក់ពីបញ្ហា និងសកម្មភាពដែលស្នើឡើងនានាសំរាប់ដាក់ជូនដល់ស្ថានទូតអូស្ត្រាលីប្រចាំនៅក្រុងភ្នំពេញ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- សំរបសំរួលការចាត់ចែងបុគ្គលិករបស់គំរោង ។
- ក្នុងករណីចាំបាច់ត្រូវជួបប្រជុំជាមួយនឹងតំណាងមកពីរដ្ឋាភិបាលទាំងពីរ ដើម្បីរាយការណ៍ស្តីពីការរីកចំរើននិងបញ្ហាដែលនៅសេសសល់របស់គំរោងដើម្បីស្នើឱ្យមានសកម្មភាពសំរបសំរួលនូវការធ្វើឱ្យរីកចំរើននិងដើម្បីសំរេចបាននូវគោលបំណងរបស់គំរោង ។
- ធ្វើទំនាក់ទំនងជាមួយភាគីអូស្ត្រាលី ដើម្បីធានានូវការអនុវត្តន៍ការងារឱ្យមានប្រសិទ្ធិភាព ។

**ប្រការ៣:** គណៈកម្មការសំរបសំរួលគំរោងជំនួយផ្នែកព្រហ្មទ័ណ្ឌនិងយុត្តិធម៌មានទីស្នាក់ការនៅក្រសួងមហាផ្ទៃសំរាប់កិច្ចការប្រចាំថ្ងៃរបស់ខ្លួន និងអាចប្រើប្រាស់មន្ត្រីរបស់ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ដែលមានជំនាញពាក់ព័ន្ធជាមួយគំរោង ។

**ប្រការ៤:** គណៈកម្មការសំរបសំរួលគំរោងជំនួយព្រហ្មទ័ណ្ឌនិងយុត្តិធម៌ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃសំរាប់រាល់លិខិតឆ្លើយឆ្លងការរបស់ខ្លួន ។

**ប្រការ៥:** គណៈកម្មការសំរបសំរួលគំរោងជំនួយផ្នែកព្រហ្មទ័ណ្ឌនិងយុត្តិធម៌អាចនឹងស្នើឱ្យមានសមាជិកប្រឹក្សាដូចដែលបានតែងតាំងខាងក្រោមនេះ និងមន្ត្រីនាយកដ្ឋានដែលពាក់ព័ន្ធផ្សេងៗទៀត ដើម្បីឱ្យផ្តល់យោបល់និងគាំទ្រដល់គណៈកម្មការនេះ ៖

១- លោកជំទាវ គីម សន្ធាវី នាយិកាសាលាភូមិន្ទចៅក្រម សមាជិកប្រឹក្សា

២- លោក អ៊ិត រ៉ាឌី អគ្គលេខាធិការរងកិច្ចការតុលាការ ក្រសួងយុត្តិធម៌ សមាជិកប្រឹក្សា

៣- ឧត្តមសេនីយ៍ទោ ម៉ៅ ច័ន្ទណារិន ប្រធាននាយកដ្ឋានបុគ្គលិក នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ សមាជិកប្រឹក្សា

៤- ឧត្តមសេនីយ៍ទោ ម៉ៅ ឈឿន ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ ក្រសួងមហាផ្ទៃ សមាជិកប្រឹក្សា

៥- ឧត្តមសេនីយ៍ត្រី អ៊ុន សុគន្ធា ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ សមាជិកប្រឹក្សា

៦- លោក តុំ ពាច ប្រធាននាយករដ្ឋបាលនិងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌ សមាជិកប្រឹក្សា

៧- លោក សោម ខាន់ដា អនុប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ សមាជិកប្រឹក្សា

**ប្រការ៦:** គណៈកម្មការសំរបសំរួលគំរោងត្រូវបានគាំទ្រដោយក្រុមគ្រប់គ្រងគំរោង (PMT) ដែលមានមន្ត្រីសមភាគីកម្ពុជា ប្រធានក្រុមអូស្ត្រាលី និងទីប្រឹក្សាគំរោង ។ ក្រុមគ្រប់គ្រងត្រូវទទួលខុសត្រូវដល់ការគ្រប់គ្រងគំរោងនិងការអនុវត្តន៍ ការរៀបចំផែនការការងារ និងការវាយតំលៃលើការអនុវត្តន៏របស់គំរោង ។

មន្ត្រីសមភាគីកម្ពុជា មានសមាសភាពដូចតទៅ :

១- ឯកឧត្តម អ៊ី ឆន អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌

២- លោក គុយ ម៉ុនសន អនុប្រធាននាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ

៣- លោក ទី គេង អនុប្រធាននាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ

៤- វរៈសេនីយ៍ឯក ម៉ុក ដារ៉ា អនុប្រធាននាយកដ្ឋាននគរបាលព្រហ្មទ័ណ្ឌ ក្រសួងមហាផ្ទៃ

ក្រុមគ្រប់គ្រងគំរោងនឹងត្រូវចូលរួមកិច្ចប្រជុំរបស់គណៈកម្មការសំរបសំរួលគំរោងផងដែរ ដោយផ្តល់នូវសេវាគាំទ្រផ្នែកលេខាធិការ និងការពិភាក្សាលើឯកសារ ហើយនិងសេចក្តីសំរេចនានារបស់គណៈកម្មការសំរបសំរួលគំរោង ។

**ប្រការ៧:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ប្រការ៥និងប្រការ៦ ត្រូវអនុវត្តតាមសេចក្តីសម្រេចឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ២០០២

ជ. នាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី

ស ខេង

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងប្រការ១ ប្រការ៥ និងប្រការ៦
- កាលប្បវត្ត-ឯកសារ